ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ : ១៨០
ចុះថ្ងៃទី០២ខែកក្កដាឆ្នាំ១៩៩៩

សាលដីកា
លេខ : ៧៥
ចុះថ្ងៃទី១៨ខែមេសាឆ្នាំ២.០០០

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ ២.០០០ ដែលមានសមាសភាពដូចខាងក្រោម :

១ - ឯកឧត្តម ឌិត មុន្ទី ប្រធាន
២ - លោក ប៉ែន ស៊ុន ចៅក្រមរបាយការណ៍
៣ - លោក ទៀល មួន ចៅក្រម
៤ - លោក ប្រាក់ គឹមសាន ចៅក្រម
៥ - លោក យស់ សុខឿន ចៅក្រម

ក្រឡាបញ្ជី
លោក ទៀង វុធ

តំណាងមហាអយ្យការ
លោក ប៉ែន សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្ដឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ : ២០៧ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ : ៤៤២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្ដឹងសាទុក្ខឈ្មោះ អ៊ឹក វ៉ន អាយុ ៤១ឆ្នាំ សញ្ជាតិកម្ពុជា របររកស៊ីធ្វើស្រែ ទីលំនៅ ភូមិព្រៃភ្លូង ឃុំបូរ ស្រុកទ្រាំង ខេត្តតាកែវ ឪពុកឈ្មោះ ធូ អ៊ឹក "ស" ម្ដាយឈ្មោះ គី សាន "ស" ។

និងចុងចម្លើយបណ្ដឹងសាទុក្ខឈ្មោះ អ៊ឹម ផុន អាយុ៣៩ឆ្នាំ សញ្ជាតិកម្ពុជា របររកស៊ីធ្វើស្រែ ទីលំនៅ ភូមិក្បាលពោធិ៍ ឃុំបូរ ស្រុកទ្រាំង ខេត្តតាកែវ ឪពុកឈ្មោះ អ៊ឹម ស៊ាង "ស" ម្ដាយឈ្មោះ នាក់ ធឿង "ស" ។ ដែលមានឈ្មោះ ឯង សារ៉ាវុធ ជាអ្នកតំណាង ។

<u>កម្មវត្ថុបណ្ដឹង</u> : ប្ដឹងជំទាស់នឹងសាលក្រមដែលចូលជាស្ថាពរ ។

តាមបណ្ដឹងសាទុក្ខលេខ : ១៦០ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៩ របស់ឈ្មោះ -

អ៊ិក រ៉ន បានប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីរបស់ សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ : ១៨០ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៩ របស់ តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ២៥_០២_៩៨ របស់ដើមចោទឈ្មោះ អ៊ិក រ៉ន ជា_តតិយជន ដែលប្ដឹងពី សាលក្រមស្ថាពរលេខ : ៧២ ចុះថ្ងៃទី ១១_០៧_៩៦ របស់តុលាការខេត្តតាកែវ សុំទាមទារដីស្រែប្រាំងទំហំ ៧០ម គុណ ៨៥ម ស្មើនឹងដីស្រែចំនួន ៣ អំពក ពីចុងចម្លើយឈ្មោះ អ៊ុម ផុន ដោយសំអាងហេតុថា កាលពីឆ្នាំ ១៩៨៧ ខ្លួនបានទិញដីស្រែនេះពីឈ្មោះ អ៊ុម ផុន ក្នុងតំលៃជាប្រាក់ចំនួន ៦៦.០០០៛០០ " ហុកសិបប្រាំមួយពាន់រៀលគត់ " ពេលទិញខ្លួនធ្វើស្រែអស់រយៈមួយឆ្នាំទើបខ្លួនលក់ដីស្រែនេះអោយបងបង្កើតរបស់ខ្លួនឈ្មោះ_អ៊ិក សូត្រ ក្នុងតំលៃជាមាស ៤ជី ហើយឈ្មោះ អ៊ិក សូត្រ ធ្វើស្រែជាទៀងទាត់មកដល់ពេលនេះ

បានឃើញ សាលក្រមលេខ : ២៥ ចុះថ្ងៃទី ២២_០៧_៩៨ របស់ តុលាការខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១ _ បដិសេធពាក្យបណ្ដឹងចុះថ្ងៃទី ២៥_០២_៩៨ របស់តតិយជនឈ្មោះ អ៊ិក រ៉ន ជាដើមចោទចោលជាអសារបង់ ។

២ _ ប្រគល់ដីស្រែប្រាំងទំហំ ៧០ម គុណ ៨៥ម ស្មើនឹងដីស្រែចំនួនបីអំពក ស្ថិតនៅភូមិក្បាលពោធិ ឃុំបូរ ស្រុកទ្រាំងខេត្តតាកែវ អោយទៅចុងចម្លើយឈ្មោះ អ៊ុម ផុន គ្រប់គ្រងនិងកាន់កាប់ជាកម្មសិទ្ធិស្របតាមអំណាច សាលក្រមលេខ : ៧២ ចុះថ្ងៃទី ១១_០៧_៩៦ របស់តុលាការខេត្តតាកែវចាប់ពីពេលនេះតទៅ ។

៣ _ ចំពោះប្រាក់ប្រដាប់ក្តីចំនួន ៧.០០០៛០០ ដើមចោទឈ្មោះ អ៊ិក រ៉ន ជាតតិយជនបានបង់រួចហើយ កាលបើផុតបណ្ដឹងឧទ្ធរណ៍បង្គាប់អោយចុងចម្លើយឈ្មោះ អ៊ុម ផុន បង់ប្រាក់ចំនួន ៧.០០០៛០០ នេះទៅដើមចោទឈ្មោះ អ៊ិក រ៉ន វិញ និង បង្គាប់អោយដើមចោទឈ្មោះ អ៊ិក រ៉ន បង់ពន្ធលមាយាទ្រូតកំណត់ មួយភាគរយ លើតំលៃដីទាស់ ដី ប្រាក់នេះ ៨០_ភាគរយ ដាក់ចូលថវិការដ្ឋ និង ២០ ភាគរយ រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

សាលក្រមនេះ ជំនុំជំរះ ជាសាធារណៈ ចំពោះមុខដើមចោទ និង ចុងចម្លើយ បើកសិទ្ធិអោយប្ដឹងឧទ្ធរណ៍ កំណត់រយៈពេល ៦០ ថ្ងៃ គិតពីថ្ងៃប្រកាស សាលក្រមនេះតទៅ ។

បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ : ២៦ ចុះថ្ងៃទី ១៨_០៨_៩៨ របស់ឈ្មោះ_អ៊ិក រ៉ន ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ : ២០៧ ចុះថ្ងៃទី ២៦_៤_៩៩ របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្ដីសំរេចដូចតទៅ :

១ _ ទទួលបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះ អ៊ិក រ៉ន ចុះថ្ងៃទី ១៨_៨_១៩៩៨ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២ - តំកល់សាលក្រមលេខ : ២២ ចុះថ្ងៃទី ២២-៧-១៩៩៨ របស់ តុលាការ ខេត្ត តាកែវ ទុកជាបានការ ។

៣ - កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛០០ ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់ទុករួច គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹង ២.៥៥០ ៛០០ រង្វាន់ក្រឡាបញ្ជី កាន់ពិបប្រាក់ ៤៥០៛០០ ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ៥.០០០៛០០ និង ចំណាយលើភាជន៍ធន តុលាការ ៥.០០០៛០០ សរុប ១៣.០០០៛០០ ។

៤ - សាលដីកានេះ ជំនុំជំរះ និង ប្រកាសជា សាធារណៈចំពោះមុខគូក្តី បើក ផ្លូវសារទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសារទុក្ខលេខ : ១៦០ ចុះថ្ងៃទី ២៤-៥-៩៩ របស់ឈ្មោះ អ៊ឹក វ៉ន ប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ធ្វើឡើងក្នុង កំណត់ច្បាប់ ។

បានឃើញ សារណាចុះថ្ងៃទី ១០-៧-៩៩ របស់ឈ្មោះ អ៊ឹក វ៉ន

បានឃើញ សារណាតបរបស់ឈ្មោះ អ៊ឹម ផុន ចុះថ្ងៃទី ១៧-០៨-៩៩

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់ តំណាងមហាអយ្យការ ថា :

បណ្តឹងសារទុក្ខរបស់ដើមចោទស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

សាលដីកាលេខ : ២០៣ ចុះថ្ងៃទី ២៦-៤-៩៩ របស់ សាលាឧទ្ធរណ៍ ដែលបានសំរេច សេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង អង្គច្បាប់ហើយ ។ សូមក្រុមប្រឹក្សា ជំនុំជំរះ សំរេចតាមច្បាប់ ។

ក្រឡាបញ្ជី អានសារណារបស់ឈ្មោះ អ៊ឹក វ៉ន

ឈ្មោះ នង សារ៉ាវុធ បានឆ្លើយថា សូមអោយតុលាការ ជួយរកយុត្តិធម៌អោយខ្លួនផង បញ្ជាក់ថា ដីនេះមិនមែនលក់អោយ សំ ចន្ថា ទេ គឺ ខ្លួនបញ្ចាំអោយគាត់ទេ ។

ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ សារណារបស់លោក អ៊ឹក វ៉ន និង ចម្លើយរបស់លោក នង សារ៉ាវុធ តំណាងអោយអ្នកស្រី អ៊ឹម ផុន

ក្រោយពីបាន ពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសារទុក្ខលេខ ១៦០ ចុះថ្ងៃទី ២៤-៥-៩៩ របស់ ឈ្មោះ អ៊ឹក វ៉ន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ ជំនុំជំរះ បានតាមមាត្រា ១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់ សាលាជំរះក្តី ។

- យល់ឃើញថា សាលក្រមលេខ ៧២ ចុះថ្ងៃទី ១១-៧-៩៦ របស់ តុលាការ ខេត្តតាកែវ ដែលមានឈ្មោះ អ្នកស្រី ជាដើមចោទ ហើយឈ្មោះនេះ

មិនប្តឹងតវ៉ាក្នុងកំណត់ច្បាប់សាក្រមនេះបានចូលជាស្ថាពររួចហើយ ។ ដូច្នេះការសំរេចសេចក្តីតាមអំណាច សាលក្រមលេខ : ២៨ ចុះថ្ងៃទី ២២ _ ៧ _ ៩៨ របស់តុលាការខេត្តតាកែវ ដែលសំរេចប្រគល់ដីអោយទៅ អ៊ឹម ផុន នោះមានការខុសឆ្គងនឹងគតិច្បាប់ ព្រោះថា ឈ្មោះ _ អ្នករ៉ន ពុំមានគុណភាពក្នុងការធ្វើបណ្តឹងនេះទេ ពីព្រោះថា ឈ្មោះនេះក៏ទទួលថាខ្លួនក៏បានលក់ដីនេះបន្តអោយ អ៊ួក ល្អត្រ រួចហើយ ដូច្នេះ តុលាការ ពុំចាំបាច់ពិចារណា និង សំរេចអំពីការប្រគល់ដីទំនាស់នេះដែរ ប៉ុន្តែដោយការសំរេចនេះមិនប៉ះពាល់ដល់ សាលក្រមស្ថាពរ និង ចុងបណ្តឹង _ ឧទ្ធរណ៍នោះ គប្បីតម្កល់ទុកជាបានការ ។

- យល់ឃើញថា ការលើកឡើងក្នុងសារណារបស់ឈ្មោះ អ៊ួក រ៉ន សុទ្ធតែជារឿងទីនអង្គហេតុ ដែល តុលាការថ្នាក់ក្រោមបាន ពិចារណារួចហើយ ។

- យល់ឃើញថា លោក អ៊ួក រ៉ក បានធ្វើសារណាការពាររឿងក្តីរបស់លោកជូនមក តុលាការកំពូល រួចហើយប៉ុន្តែពុំបានចូលរួម សវនាការ នេះទេ ដូច្នេះ តុលាការកំពូល _ ជំនុំជំរះ រឿងនេះកំបាំងមុខលោក ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ២០៧ ចុះថ្ងៃទី ២៦ _ ៤ _ ៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាម ទំរង់ និង គតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខតំណាងអ្នកស្រី អ៊ឹម ផុន កំបាំងមុខលោក អ៊ួក រ៉ន ប៉ុន្តែ ចាត់ទុកជាចំពោះមុខ

១ _ ទទួលបណ្តឹងសាទុក្ខលេខ : ១៦០ ចុះថ្ងៃទី ២៤ _ ៥ _ ៩៩ របស់ឈ្មោះ _ អ៊ួក រ៉ន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ _ តម្កល់ សាលដីការដ្ឋប្បវេណីលេខ : ២០៧ ចុះថ្ងៃទី ២៦ _ ៤ _ ៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ _ រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛០០ ដែលលោក អ៊ួក រ៉ន បានបង់រួច _ ហើយ គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន ៤.០០០៛០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛០០ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛០០ សរុប ១៩.០០០៛០០ ។

បង្គាប់អោយឈ្មោះ អ៊ួក រ៉ន បង់ពន្ធសមាមាត្រ តាមការកំណត់ របស់តុលាការ _ ខេត្ត តាកែវ ។

- ----- -

៥ - សាលដីកានេះ ប្រកាសនា សវនាការ ជាសាធារណៈ នៅថ្ងៃទី១៨-ខែមេសា ឆ្នាំ ២.០០០ ។